# ២ - សេចក្តីសំរេច

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៣*

## សេចក្តីសំរេចលេខ ៣៦ សសរ

## ស្តីពី

## ការបង្កើតគណៈកម្មការជាតិប្រយុទ្ធ

## និងជម្ងឺអេដស៍

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១- ៩៣
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ២៤-៩- ៩៣
- ផ្អែកតាមតម្រូវការចាំបាច់

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការជាតិមួយឈ្មោះថា " គណៈកម្មការជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ " ដែលមានសភាពដូចខាងក្រោម :

| | |
|---|---|
| ១- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល | ប្រធាន |
| ២- ឯកឧត្តមរដ្ឋលេខាធិការក្រសួងអប់រំ | អនុប្រធាន |
| ៣- ឯកឧត្តមរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន | អនុប្រធាន |
| ៤- ឯកឧត្តមរដ្ឋលេខាធិការក្រសួងពត៌មាន | សមាជិក |
| ៥- ឯកឧត្តមរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦- ឯកឧត្តមរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧- ឯកឧត្តមរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |

៨- ឯកឧត្តមរដ្ឋលេខាធិការក្រសួងផែនការ សមាជិក

៩- ឯកឧត្តមរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១០- ឯកឧត្តមរដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១១- ឯកឧត្តមរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន កិច្ចការនារី សមាជិក

១២- ឯកឧត្តមរដ្ឋលេខាធិការក្រសួងវប្បធម៌ សមាជិក

១៣- អភិបាលរង-ខេត្ត- ក្រុងនិងរាជធានី សមាជិក

**ប្រការ២ :** គណៈកម្មការជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ មានលេខាធិការដ្ឋានជំនួយការដែលមានសមាសភាពដូចខាងក្រោមនេះ ÷

១-លោក វេជ្ជបណ្ឌិត ហ៊ុន ឈុនលី ប្រធានលេខាធិការដ្ឋាន

២- លោក វេជ្ជបណ្ឌិត ហេង ស៊ុន មន្ត្រីក្រសួងសុខាភិបាលអនុប្រធាន

៣- លោកវេជ្ជបណ្ឌិត ទា ផល្លា មន្ត្រីក្រសួងសុខាភិបាលសមាជិក

៤- លោក វេជ្ជបណ្ឌិត តាន់ ទ្រី មន្ត្រីក្រសួងសុខាភិបាលសមាជិក

៥- លោកស្រីឱសថការី ត្រុយ ស៊ីនឡាយ មន្ត្រីក្រសួងសុខាភិបាលសមាជិក

៦- លោកវេជ្ជបណ្ឌិត ហោ ប៊ុនឡេង មន្ត្រីក្រសួងសុខាភិបាលសមាជិក

**ប្រការ ៣ :** គណៈកម្មការជាតិប្រយុទ្ធនឹងជម្ងឺអេដស៍មានភារកិច្ច :

- ទទួលខុសត្រូវរួមមានលើវិធានការការពារ និងត្រួតពិនិត្យស្រាវជ្រាវជម្ងឺអេដស៍ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលកម្ពុជា អំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងសភាពការណ៍ជម្ងឺអេដស៍
- ផ្តល់យោបល់ណែនាំដល់មន្ទីរពិសោធន៍ និងមន្ទីរពេទ្យដែលទទួលព្យាបាលថែទាំអ្នកផ្ទុកមេរោគអេច-អៃ-វី ឬ អ្នកកើតជម្ងឺអេដស៍ ។

លេខាធិការដ្ឋានមានភារកិច្ច :

- ផ្តល់ពត៌មានស្តីពីសកម្មភាពអនុវត្តការងារប្រឆាំងនឹងជម្ងឺអេដស៍ ។

- ទទួលខុសត្រូវក្នុងការតាមដាន និងអនុវត្តនូវសកម្មភាពទាំងឡាយ ក្នុងកម្មវិធីប្រយុទ្ធ និងការរាតត្បាតនៃជម្ងឺ ។
- លើកកម្មវិធីរយៈពេលខ្លី - មធ្យម- វែង ដើម្បីទប់ស្កាត់ការសាយភាយនៃជម្ងឺអេដស៍និងលើកគំរោងថវិកា ។
- សហការយ៉ាងជិតស្និទ្ធជាមួយអង្គការសុខភាពពិភពលោក និងអង្គការអន្តរជាតិនានាដើម្បីទាក់ទងជំនួយ ។

**ប្រការ ៤ :** ក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធក្នុងកិច្ចការពារជម្ងឺអេដស៍ ត្រូវចាត់តាំងក្រុមជំនួយការអោយលេខាធិការដ្ឋាន នៃគណៈកម្មការជាតិប្រយុទ្ធនឹងជម្ងឺអេដស៍អោយធ្វើសេចក្តីរាយការណ៍ ទៀងទាត់និងជាប្រចាំ ។

**ប្រការ ៥ :** គណៈកម្មការជាតិប្រយុទ្ធនឹងជម្ងឺអេដស៍មានទីស្នាក់ការអចិន្ត្រៃយ៍នៅក្រសួងសុខាភិបាលនិងមានសិទ្ធិប្រើប្រាស់ ត្រារបស់ក្រសួងសុខាភិបាល ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ក្រសួងការងារសង្គមកិច្ច មហាផ្ទៃ-អប់រំបណ្ដាក្រសួង- ស្ថាប័ន និងអភិបាលគ្រប់ខេត្តក្រុងដែលមានការពាក់ព័ន្ធព្រមទាំងឯកឧត្តម អស់លោក លោកស្រី ដែលមានរាយនាមក្នុងប្រការ ១ និងប្រការ ២ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

ជ.រាជរដ្ឋាភិបាលកម្ពុជា

ឧបនាយករដ្ឋមន្ត្រី

ព្រះហស្តលេខា និង ត្រា

ព្រះអង្គម្ចាស់ **នរោត្តម សិរីវឌ្ឍ**

ហត្ថលេខា និង ត្រា

ឯកឧត្តម **ស ខេង**